ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

# វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារឆ្នាំ២០១៨ និងទស្សនវិស័យឆ្នាំ២០១៩

រៀបចំដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ត្រូវនឹងថ្ងៃទី២ ខែមករា ឆ្នាំ២០១៩

សេដ្ឋកិច្ចកម្ពុជាបានបន្តរីកចម្រើនគួរជាទីមោទនៈ។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានភាពរឹងមាំ ទោះបីជាបានប្រឈមនឹងហានិភ័យមួយចំនួនក្តី។ វិស័យកាត់ដេរ សំណង់ និងទេសចរណ៍បន្តមានកំណើនក្នុងអត្រាពីរខ្ទង់ ក្នុងបរិយាកាសអំណោយផលនៃកំណើនសេដ្ឋកិច្ចពិភពលោក និងដោយមានការគាំទ្រពីគោលនយោបាយសារពើពន្ធវិត្ថារកម្ម គោលនយោបាយរូបិយវត្ថុ និងផ្លែផ្កានៃវឌ្ឍនភាពវិស័យធនាគារនិងវិស័យដទៃទៀត។ កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៨ ត្រូវបានប៉ាន់ស្មានថាកើនឡើងក្នុងអត្រា ៧,៣% ដែលជាកម្រិតខ្ពស់ធៀបនឹងអត្រាកំណើនក្នុងរយៈពេល ៦ឆ្នាំចុងក្រោយ និងខ្ពស់ជាងអត្រាកំណើនមធ្យមនៃប្រទេសកំពុងលូតលាស់និងប្រទេសក្នុងតំបន់ទៀតផង។

ទោះជាបានប្រឈមនឹងភាពតានតឹងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក-ចិន និងឥទ្ធិពលនៃប្រក្រតីកម្មគោលនយោបាយរូបិយវត្ថុក្នុងប្រទេសអភិវឌ្ឍន៍មួយចំនួនក៏ដោយ កំណើនសេដ្ឋកិច្ចពិភពលោកនិងតំបន់បន្តមានភាពល្អប្រសើរ និងបានផ្តល់កាលានុវត្តភាពល្អដល់សេដ្ឋកិច្ចកម្ពុជា។ លំហូរចូលនៃវិនិយោគផ្ទាល់បរទេសបន្តកើនឡើងក្នុងអត្រាខ្ពស់ (១២%) ជាពិសេសទៅកាន់វិស័យធនាគារ អចលនទ្រព្យ និងកាត់ដេរ ហើយបានគាំទ្រជញ្ជីងទូទាត់ឱ្យមានអតិរេកប្រមាណ ៨,៥% នៃផ.ស.ស.។ អតិរេកជញ្ជីងទូទាត់បានរួមចំណែកគរពូនទុនបម្រុងអន្តរជាតិដល់ ១០ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការនាំចូលទំនិញនិងសេវាសម្រាប់ឆ្នាំបន្ទាប់បាន ៥,៨ខែ ដែលជាកម្រិតខ្ពស់ធៀបនឹងកម្រិតអប្បបរមាដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន (៣ខែ)។

គួររំលេចថា តាមរយៈការសិក្សារបស់ធនាគារពិភពលោក ភាពតានតឹងពាណិជ្ជកម្មរវាងសហរដ្ឋអាមេរិក-ចិន បាននិងកំពុងនាំឱ្យមានបម្លាស់ទីនៃការវិនិយោគ និងកំណើននៃការនាំចេញក្នុងតំបន់។ ទន្ទឹមនេះ ការសិក្សារបស់ធនាគារជាតិនៃកម្ពុជាក៏បានបង្ហាញថា កម្ពុជាអាចទទួលបានកំណើនវិនិយោគក្នុងវិស័យកម្មន្តសាលនិងកសិកម្ម ដោយសារកម្ពុជាអាចផលិតនិងនាំចេញទំនិញមួយចំនួនក្នុងវិស័យទាំងនេះ ដែលមិនស្ថិតក្នុងគោលដៅដែលត្រូវដំឡើងពន្ធទាំងនៅសហរដ្ឋ-អាមេរិកនិងចិន។ ជាក់ស្តែង ការនាំចេញរបស់កម្ពុជាបានកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសផលិតផលកាត់ដេរត្រូវបានប៉ាន់ស្មានថាកើនឡើង ២៥,៧% ស្របពេលដែលការនាំចេញផលិតផលមួយចំនួនបានកើនឡើងក្នុងអត្រាពីរទៅបីខ្ទង់ ដូចជា ការនាំចេញអង្ករកើន ២៣% ទោចក្រយានកើន ១២% និងគ្រឿងបន្លាស់យានយន្តកើន ៣ដង។ ថ្វីបើការនាំចេញផលិតផល



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

កាត់ដេរនៅបន្តមានចំណែកធំ ប្រមាណ ២/៣ នៃការនាំចេញសរុបក៏ដោយ ក៏ចំណែកនេះបានថយចុះគួរឱ្យកត់សម្គាល់ បើធៀបនឹងប្រមាណ ៩៦% កាលពី ១០ឆ្នាំមុន។ ចំពោះវិស័យទេសចរណ៍ ភ្ញៀវទេសចរអន្តរជាតិបន្តកើនឡើងខ្ពស់ក្នុងអត្រា ១១,៥% (ដល់ ៦,២ លាននាក់) ស្របពេលដែលគោលដៅទេសចរណ៍សំខាន់ៗរបស់កម្ពុជាក៏ត្រូវបានអភិវឌ្ឍ។ និន្នាការទាំងនេះបង្ហាញពីផ្លែផ្កានៃគោលនយោបាយពិពិធកម្មរបស់រាជរដ្ឋាភិបាល ដើម្បីពង្រីកមូលដ្ឋានកំណើនសេដ្ឋកិច្ច។

កម្រិតថ្លៃនិងអត្រាប្តូរប្រាក់បន្តរក្សាបានស្ថិរភាពល្អប្រសើរ។ អត្រាអតិផរណាបន្តមានកម្រិតទាបប្រមាណ ២,៥% ទាបជាងឆ្នាំ២០១៧ (២,៩%) ដោយសារថ្លៃម្ហូបអាហារកើនឡើងយឺត (២,៧%) ទោះបីជាថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈបានកើនឡើងខ្ពស់បន្តិចក្តី (៣,៧%)។ គួរបញ្ជាក់ថា ទោះជារូបិយប័ណ្ណរបស់ប្រទេសមួយចំនួនក្នុងតំបន់កំពុងធ្លាក់ថ្លៃ ដែលបណ្តាលមកពីសម្ពាធនៃការដំឡើងអត្រាការប្រាក់គោលរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិកក៏ដោយ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកបន្តមានស្ថិរភាពក្នុងរង្វង់ ៤.០៥០ រៀល។

ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយសារពើពន្ធវិត្តារកម្មសមស្របបានចូលរួមចំណែករក្សាស្ថិរភាពថ្លៃរឹងមាំ គាំទ្រការវិនិយោគ និងការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច។ រូបិយវត្ថុទូទៅ (M2) បានកើនឡើង ២៤,២% ប្រហាក់ប្រហែលនឹងអត្រាកំណើននាឆ្នាំកន្លងទៅ (២៣,៨%) ដែលស្ថិតក្នុងកម្រិតសមស្របនឹងការរីកចម្រើននៃសេដ្ឋកិច្ច ដោយមិនបណ្តាលឱ្យមានសម្ពាធដល់អតិផរណា។ ក្នុងពេលដែលទីផ្សារអន្តរធនាគារមិនទាន់សកម្មនៅឡើយ ធនាគារជាតិនៃកម្ពុជាបន្តអភិវឌ្ឍឧបករណ៍គោលនយោបាយរូបិយវត្ថុ ដើម្បីសម្រួលដល់ការគ្រប់គ្រងសន្ទនីយភាពនៅក្នុងប្រព័ន្ធធនាគារឱ្យកាន់តែមានប្រសិទ្ធភាព។

ស្របពេលដែលទំនាក់ទំនងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកាន់តែមានភាពស៊ីជម្រៅ ស្ថិរភាពនិងការរីកចម្រើនវិស័យធនាគារបានចូលរួមចំណែកយ៉ាងសំខាន់ ដល់ការសម្រេចបាននូវវឌ្ឍនភាពសេដ្ឋកិច្ចកម្ពុជា។ វិស័យធនាគារបន្តចាក់ឫសទៅក្នុងសេដ្ឋកិច្ចយ៉ាងរឹងមាំ ដោយបានជំរុញឱ្យភាពស៊ីជម្រៅផ្នែកហិញ្ញវត្ថុ (M2/GDP) កើនដល់ ៧៨% ធៀបនឹង ៧៣% នៅឆ្នាំ២០១៧ ហើយទ្រព្យសកម្មសរុបបានកើនឡើងដល់ ១៧៥% នៃផ.ស.ស. (កើន ២០%)។ ទន្ទឹមនេះ ជំនឿទុកចិត្តសាធារណជនមកលើប្រព័ន្ធធនាគារ ក៏ត្រូវបានពង្រឹងជាលំដាប់ ដោយបានជំរុញឱ្យប្រាក់បញ្ញើកើនដល់ ៩១% នៃផ.ស.ស. (កើន ១៦%) ដែលផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុធ្វើអន្តរការិយកម្មហិរញ្ញវត្ថុកាន់តែសកម្ម។ ឥណទានចំពោះវិស័យឯកជនបានកើនឡើងដល់ ១០២% នៃផ.ស.ស. (កើន ២០,១%) ដែលបានគាំទ្រដល់ការធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន។ ជាមួយគ្នានេះ វិស័យធនាគារក៏បានរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយបានបង្កើនបរិយាប័ន្នហិរញ្ញវត្ថុជាលំដាប់ ដែលបច្ចុប្បន្ន ៦៩% នៃប្រជាជនពេញវ័យទទួលបានសេវាហិរញ្ញវត្ថុ ស្របពេលដែលចំណេះដឹងពីការប្រើប្រាស់សេវាហិរញ្ញវត្ថុត្រូវបានពង្រឹងជាប្រចាំ។

ដើម្បីគាំទ្រការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ ហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុត្រូវបានអភិវឌ្ឍនិងធ្វើទំនើបកម្ម ជាពិសេសប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងការទូទាត់អេឡិចត្រូនិក។ ប្រព័ន្ធចែករំលែកឥណទានត្រូវបានពង្រីកវិសាលភាព ដោយបង្កើនការចែករំលែកព័ត៌មាន

ឥណទានសហគ្រាស បន្ថែមលើព័ត៌មានឥណទានឯកត្តបុគ្គលដែលមានស្រាប់ ដើម្បីរួមចំណែកកាត់បន្ថយហានិភ័យឥណទាន បង្កើនតម្លាភាព និងបន្ទាបអត្រាការប្រាក់ឥណទានបន្ថែមទៀតនាពេលអនាគត។ លើសពីនេះ ប្រព័ន្ធខេមបូឌានស៊ែស្វិច (CSS) ត្រូវបានដាក់ឱ្យដំណើរការបឋមសម្រាប់បង្កើនប្រសិទ្ធភាពប្រតិបត្តិការទូទាត់អន្តរធនាគារ តាមរយៈប័ណ្ណទូទាត់ឥណពន្ធ ស្របពេលដែលប្រព័ន្ធទូទាត់ដុលភ្លាមៗ (RTGS) កំពុងត្រូវបានអភិវឌ្ឍ ដើម្បីសម្រួលដល់ប្រតិបត្តិការទូទាត់សងប្រាក់តម្លៃធំអន្តរធនាគារ។ ប្រព័ន្ធធនាគារអនឡាញ (OBS) ដែលផ្តល់សេវាផ្ទេរប្រាក់អនឡាញក៏បានពង្រីកវិសាលភាព និងអនុញ្ញាតឱ្យសមាជិកដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រសួង-មន្ទីររបស់រាជរដ្ឋាភិបាល អាចផ្ទេរប្រាក់និងទទួលប្រាក់បានភ្លាមៗពីគណនីមួយទៅគណនីមួយទៀតដែលបើកនៅធនាគារជាតិនៃកម្ពុជា និងរួមចំណែកក្នុងការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនេះ ប្រព័ន្ធ NBC Platform បានដាក់ឱ្យដំណើរការ សម្រាប់សម្រួលនិងជំរុញដល់ប្រតិបត្តិការអន្តរធនាគារ ដូចជា លើការទិញ-លក់រូបិយប័ណ្ណនិងមូលបត្រអាចជួញដូរបាន និងចូលរួមក្នុងប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានាផងដែរ។ ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាកំពុងសិក្សាលើការបង្កើតស្តង់ដារ QR code សម្រាប់ការទូទាត់ និងលើគម្រោង "បាគង" ស្តីពីលទ្ធភាពនៃការចេញផ្សាយរូបិយវត្ថុឌីជីថលរបស់ធនាគារកណ្តាល ដែលការសិក្សាទាំងពីរនេះនឹងអនុញ្ញាតឱ្យគ្រឹះស្ថានផ្តល់សេវាទូទាត់ រួមទាំងគ្រឹះស្ថានធនាគារ ធ្វើប្រតិបត្តិការទូទាត់ឆ្លងប្រព័ន្ធគ្នាបាន។ ម្យ៉ាងទៀត ប្រព័ន្ធទូទាត់តម្លៃរាយ ដែលអនុញ្ញាតឱ្យគ្រឹះស្ថានធ្វើប្រតិបត្តិការទូទាត់ឆ្លងប្រព័ន្ធគ្នាក៏ត្រូវបានអភិវឌ្ឍ ហើយនាពេលអនាគត ប្រព័ន្ធនេះអាចភ្ជាប់ទំនាក់ទំនងជាមួយប្រព័ន្ធទូទាត់រាយរបស់ប្រទេសក្នុងតំបន់ ដើម្បីធ្វើប្រតិបត្តិការទូទាត់និងផ្ទេរប្រាក់ឆ្លងប្រទេសដោយផ្ទាល់ ដែលនឹងចូលរួមកាត់បន្ថយថ្លៃសេវាផ្ទេរប្រាក់ឆ្លងប្រទេស។

ចំពោះទស្សនវិស័យសម្រាប់ឆ្នាំ២០១៩ សេដ្ឋកិច្ចកម្ពុជារំពឹងថាបន្តមានកំណើនក្នុងរង្វង់ ៧% ហើយអត្រាអតិផរណាបន្តស្ថិតក្នុងកម្រិតទាប ២,៦% ជាមួយនឹងស្ថិរភាពនៃអត្រាប្តូរប្រាក់ ៤.០៥០ រៀលក្នុងមួយដុល្លារអាមេរិក។ ទុនបម្រុងអន្តរជាតិរំពឹងថានឹងបន្តកើនដល់ ១១,៣ ប៊ីលានដុល្លារអាមេរិក ដែលអាចធានាការនាំចូលទំនិញនិងសេវាបានប្រមាណ ៥ខែ។ ម្យ៉ាងទៀត ឥណទានវិស័យធនាគាររំពឹងថានឹងបន្តកើនឡើងក្នុងល្បឿន ១៧,១% និងបរិយាប័ន្នហិរញ្ញវត្ថុនឹងបន្តកើនឡើងជាលំដាប់ ដែលកត្តាទាំងនេះនឹងបន្តរួមចំណែកជំរុញការរីកចម្រើនសកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្របន្ថែមទៀត។ ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជាអាចមានបញ្ហាប្រឈមមួយចំនួនផងដែរ ដែលបណ្តាលមកពីទាំងកត្តាខាងក្រៅនិងខាងក្នុង។

ហានិភ័យខាងក្រៅចម្បងៗ រួមមាន៖

i/- លំហូរចេញនៃមូលធនពីតំបន់៖ ការបន្តងើបឡើងនៃសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ បាននាំឱ្យធនាគារកណ្តាលមួយចំនួននៃប្រទេសទាំងនេះ ជាពិសេស សហរដ្ឋអាមេរិក បន្តធ្វើប្រក្រតីកម្មគោលនយោបាយរូបិយវត្ថុ តាមរយៈការដំឡើងអត្រាការប្រាក់គោល។ ការដំឡើងនេះបាននិងកំពុងធ្វើឱ្យមូលធនហូរទៅកប្រទេសទាំងនេះវិញ ដែលបានធ្វើឱ្យប្រភពទុនលើទីផ្សារហិរញ្ញវត្ថុអន្តរជាតិនិងតំបន់ថយចុះ និងជាកត្តាធ្វើឱ្យអត្រាការប្រាក់កម្ចីក្នុងតំបន់អាចកើនឡើង។ បញ្ហានេះអាចនឹងបង្កើនថ្លៃដើមនៃកម្ចីពីក្រៅប្រទេស របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកម្ពុជា ដែលពឹងផ្អែកលើប្រភពទុនពីខាងក្រៅ។

ii/- លំហូរចេញនៃមូលធនពីតំបន់ទៅសហរដ្ឋអាមេរិក អាចនាំឱ្យប្រាក់ដុល្លារអាមេរិកឡើងថ្លៃ៖ ការឡើងថ្លៃនេះអាចបង្កើនចំណាយផលិតកម្មទំនិញនាំចេញ ដែលធ្វើឡើងជាប្រាក់ដុល្លារអាមេរិក ដូច្នេះ ប៉ះពាល់ដល់ភាពប្រកួតប្រជែងនៃការនាំចេញរបស់កម្ពុជា។ ដូចគ្នានេះដែរ ចំណាយរបស់ភ្ញៀវទេសចរ ដែលប្រើប្រាស់ប្រាក់ដុល្លារអាមេរិកក៏អាចនឹងកើនឡើងផងដែរ ធៀបនឹងប្រទេសដែលប្រើប្រាស់រូបិយវត្ថុក្នុងស្រុកដែលមានតម្លៃរូបិយប័ណ្ណធ្លាក់ថ្លៃធៀបនឹងប្រាក់ដុល្លារអាមេរិក។

iii/- ទោះបីជាលទ្ធភាពនៃការកើនឡើងថ្លៃប្រេងអន្តរជាតិ មិនមានឥទ្ធិពលទៅលើថ្លៃអគ្គិសនីនៅកម្ពុជា ដោយសារការប្រើប្រាស់ថាមពលពឹងផ្អែកភាគច្រើនទៅលើប្រភពវារីអគ្គិសនី (៤៨,៥%) និងធ្យូងថ្ម (៣៤,៥%) ក៏ដោយ ក៏ការកើនឡើងនេះអាចរួមចំណែកបង្កើនថ្លៃដឹកជញ្ជូន និងថ្លៃដើមផលិតកម្ម ដូច្នេះអាចបង្កើនសម្ពាធលើអត្រាអតិផរណាកម្ពុជាផងដែរ។

iv/- កម្ពុជាអាចប្រឈមនឹងការដកប្រព័ន្ធអនុគ្រោះពន្ធអ្វីៗគ្រប់យ៉ាងលើកលែងអាវុធ (EBA) របស់សហភាពអឺរ៉ុបពីកម្ពុជា ដែលបានប្រកាសកាលពីខែតុលា ឆ្នាំ២០១៨ ហើយត្រូវឆ្លងកាត់ការអង្កេតវាយតម្លៃ និងដំណាក់កាលបន្តបន្ទាប់ទៀត មុននឹងឈានទៅដល់ការសម្រេចដក ដែលអាចមានរយៈពេលយ៉ាងតិច ១៨ខែ និង

v/- ការអនុវត្តកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មរវាងសហភាពអឺរ៉ុបនិងសហរដ្ឋអាមេរិក ជាមួយនឹងប្រទេសជាគូប្រជែងនាំចេញរបស់កម្ពុជា៖ កិច្ចព្រមព្រៀងទាំងនេះនឹងផ្តល់អាទិភាពឱ្យប្រទេសជាគូប្រកួតប្រជែងនាំចេញរបស់កម្ពុជាមាននាំទំនេញចូលទីផ្សារធំៗ ដែលជាសមាជិក។

ចំពោះហានិភ័យខាងក្នុងមួយចំនួនដែលគួរឱ្យកត់សម្គាល់ រួមមាន៖

i/- កំណើនវិស័យសំណង់រួមចំណែកប្រមាណ ១/៥ ក្នុងកំណើនសេដ្ឋកិច្ច ដែលបង្ហាញពីការពឹងផ្អែកកាន់តែខ្លាំងនៃកំណើនសេដ្ឋកិច្ចលើវិស័យនេះ។ ជាទូទៅ វិស័យសំណង់មានវដ្តនៃការអភិវឌ្ឍ ដែលធ្វើឱ្យវិស័យនេះអាចកើនឡើង និងថយមកវិញ នៅពេលដែលគម្រោងសំណង់ធំៗត្រូវបានបញ្ចប់។

ii/- កំណើនឥណទានទៅកាន់វិស័យសំណង់និងអចលនទ្រព្យបន្តមានកម្រិតខ្ពស់នៅឡើយក្នុងអត្រា ៣១%។ ការកើនឡើងលឿននៃវិស័យសំណង់និងអចលនទ្រព្យ អាចធ្វើឱ្យតម្លៃអចលនទ្រព្យកើនឡើងហួសពីតម្រូវការជាក់ស្តែង និងអាចជាហានិភ័យសម្រាប់វិស័យធនាគារ និងជំនឿទុកចិត្តវិនិយោគិនផងដែរ និង

iii/- ថ្លៃដើមផលិតកម្មនៅកម្ពុជាមានកម្រិតខ្ពស់នៅឡើយ ដោយសារសេដ្ឋកិច្ចមាត្រដ្ឋាន (Economies of scale) នៅមានទំហំតូច, ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធនៅមានកំណត់, បញ្ហាផ្គត់ផ្គង់អគ្គិសនី (កង្វះប្រព័ន្ធចែកចាយនិងថ្លៃខ្ពស់) និងការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមា ជាដើម។

ឆ្លើយតបទៅនឹងបញ្ហាទាំងនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តរួមចំណែកគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកែទម្រង់រចនាសម្ព័ន្ធ ការធ្វើពិពិធកម្ម ការរក្សាបរិយាកាសអំណោយផលដល់ការវិនិយោគ និងផែនការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចនានាប្រកបដោយប្រសិទ្ធភាព។ សម្រាប់វិស័យធនាគារ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងជំនឿទុកចិត្តនិងអភិវឌ្ឍប្រព័ន្ធធនាគារប្រកបដោយប្រសិទ្ធភាព ភាពរឹងមាំ ភាពប្រកួតប្រជែង និងសមាហរណកម្ម ព្រមទាំងបន្តរក្សាឱ្យបានស្ថិរភាពថ្លៃ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល។

ម្យ៉ាងទៀត វិស័យធនាគារនឹងបន្តយកចិត្តទុកដាក់និងអនុវត្តការងារអាទិភាពមួយចំនួនទៀត ដើម្បីបន្តគាំទ្រកំណើនប្រកបដោយចីរភាព សមភាព និងបរិយាប័ន្ន រួមមាន៖

ទី១-ការសម្របខ្លួនទៅនឹងបដិវត្តន៍ឧស្សាហកម្មទី៤៖ បដិវត្តន៍ឧស្សាហកម្មទី៤ បាននិងកំពុងផ្លាស់ប្តូរដំណើរការនៃប្រព័ន្ធសេដ្ឋកិច្ច សង្គម និងនយោបាយ។ ការបន្តអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងការតាមដានឱ្យទាន់ពេលវេលានូវការរីកចម្រើននៃបច្ចេកវិទ្យា មានសារៈសំខាន់ណាស់ក្នុងការរក្សាប្រសិទ្ធភាពការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចទាំងមូល។ បដិវត្តន៍ឧស្សាហកម្មនេះបានបង្កើតបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ដែលមានការវិវត្តយ៉ាងឆាប់រហ័សក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ។ បច្ចេកវិទ្យាហិរញ្ញវត្ថុមួយចំនួនបានកាត់បន្ថយកម្រៃសេវានិងហានិភ័យ ព្រមទាំងជំរុញបរិយាប័ន្នហិរញ្ញវត្ថុ ប៉ុន្តែបច្ចេកវិទ្យាហិរញ្ញវត្ថុមួយចំនួនទៀតដូចជា ទ្រព្យសកម្ម Crypto បានបង្កហានិភ័យដល់សេដ្ឋកិច្ច ដោយសារការប្រែប្រួលតម្លៃយ៉ាងឆាប់រហ័ស និងគ្មានការធានាលើការប្តូរជាសាច់ប្រាក់ដោយស្ថាប័នណាមួយឡើយ។ ក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យអនុវត្តបទប្បញ្ញត្តិគ្រប់គ្រងបច្ចេកវិទ្យាហិរញ្ញវត្ថុសមស្រប និងបន្តអភិវឌ្ឍសមត្ថភាពធនធានមនុស្សជាការងារអាទិភាព ដើម្បីបង្កើនផលិតភាពនិងប្រសិទ្ធភាពការងារ សំដៅបង្ការហានិភ័យនានា, ទាញយកផលប្រយោជន៍ និងសម្របខ្លួនទៅនឹងការរីកចម្រើននៃបច្ចេកវិទ្យាថ្មីៗ។

ទី២-យ៉ែនឌ័រ៖ ការស្រាវជ្រាវរបស់មូលនិធិរូបិយវត្ថុអន្តរជាតិបានបង្ហាញថា ការលើកកម្ពស់តួនាទីស្ត្រីក្នុងវិស័យហិរញ្ញវត្ថុមានសារៈសំខាន់ណាស់ក្នុងការបង្កើនជីវភាពរស់នៅ កាត់បន្ថយវិសមភាពយ៉ែនឌ័រ ជាដើម ដែលទាំងនេះអាចរួមចំណែកបង្កើនស្ថិរភាពប្រព័ន្ធធនាគារ កំណើនសេដ្ឋកិច្ច និងសុខុមាលភាពសង្គម។ នាពេលកន្លងមក ស្ត្រីកម្ពុជាមានតួនាទីយ៉ាងសកម្មក្នុងវិស័យកម្មន្តសាល ខណៈដែលបរិយាប័ន្នហិរញ្ញវត្ថុស្ត្រីមានកម្រិតស្មើនឹងបុរស។ ដោយពិនិត្យឃើញពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងបន្តលើកកម្ពស់តួនាទីស្ត្រីក្នុងកម្រិតដឹកនាំ, សហការជាមួយក្រសួងកិច្ចការនារីក្នុងការជំរុញបរិយាប័ន្នហិរញ្ញវត្ថុស្ត្រី ព្រមទាំងបានដាក់ចេញនូវផែនការកាត់បន្ថយចំនួនស្ត្រីដែលមិនទាន់ទទួលបានសេវាហិរញ្ញវត្ថុពី ២៧% មក ១៣% នៅត្រឹមឆ្នាំ២០២៥។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ចូលរួមបង្កើនចំនួនស្ត្រីក្នុងសមាសភាពថ្នាក់ដឹកនាំរបស់ខ្លួន និងបន្តបង្កើនផលិតផលហិរញ្ញវត្ថុស្របតាមតម្រូវការរបស់អតិថិជនជាស្ត្រីឱ្យកាន់តែច្រើន នាពេលខាងមុខ និង

ទី៣-ការពង្រឹងការប្រើប្រាស់ប្រាក់រៀល៖ ស្ថិតក្នុងបរិការណ៍កម្រិតដុល្លារូបនីយកម្មខ្ពស់ ដែលបានដាក់សម្ពាធលើការអនុវត្តគោលនយោបាយរូបិយវត្ថុ ការបន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល ត្រូវបានអនុវត្តជាប្រចាំ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងការរីកចម្រើននៃសេដ្ឋកិច្ច ប៉ុន្តែក៏ត្រូវទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីបន្ថែមទៀតផងដែរ។ ធនាគារជាតិនៃកម្ពុជាបានចាត់វិធានការថ្មីៗ មានជាអាទិ៍៖ i/-ការផ្តល់សន្ទនីយភាពជាប្រាក់រៀលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលខ្វះប្រាក់រៀលក្នុងប្រតិបត្តិការ តាមរយៈប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា (LPCO) ii/-ការសហការជាមួយក្រសួងពាណិជ្ជកម្មជំរុញការអនុវត្តប្រកាសស្តីពី ការបិទស្លាកតម្លៃជាប្រាក់រៀល iii/-ការតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានសំពៀតឥណទានជាប្រាក់រៀលយ៉ាងតិច ១០% ត្រឹមបំណាច់ឆ្នាំ២០១៩ iv/-ការអភិវឌ្ឍប្រព័ន្ធសេវា

ទូទាត់រហ័ស (FAST) ដែលធ្វើឱ្យការទូទាត់ជាប្រាក់រៀលមានចំណាយទាប និងទទួលបានមូលនិធិភ្លាមៗ v/-ការអភិវឌ្ឍការទូទាត់តាមរយៈប្រព័ន្ធ QR Code ឆ្លងប្រទេសសម្រាប់ទូទាត់ពាណិជ្ជកម្មទ្វេភាគីជាប្រាក់រៀលនិងប្រាក់បាតថៃ vi/-ការសហការជាមួយធនាគារកណ្តាលចិនលើការជំរុញការប្រើប្រាស់ប្រាក់រៀលនិងប្រាក់យ៉ន់សម្រាប់ពាណិជ្ជកម្មទ្វេភាគី និង vi/-ការអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុចេញផ្សាយសញ្ញាប័ណ្ណសាជីវកម្មជាប្រាក់រៀល។